ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ :.០៣...កយ..សណន /២១

# សេចក្តីណែនាំ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
## ជម្រាបមក
## ឯកឧត្តមប្រធានសាលាដំបូងរាជធានី ខេត្ត
## ឯកឧត្តម លោកជំទាវ ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត

**កម្មវត្ថុ ៖** សេចក្តីណែនាំស្តីពីគោលការណ៍ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ដើម្បីពន្លឿនចំណាត់ការនីតិវិធីនៅក្នុងសំណុំរឿង និងដើម្បីរួមចំណែកដោះស្រាយភាពចង្អៀតណែនក្នុងពន្ធនាគារ។

កន្លងមក នៅក្នុងក្របខណ្ឌនៃការអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងព្រហ្មទណ្ឌនៅតាមសាលាដំបូងរាជធានី ខេត្ត ដែលក្រសួងយុត្តិធម៌បានដាក់ចេញកាលពី**ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០** និងត្រូវបានបិទបញ្ចប់កាល**ពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១** និងក្នុងគោលដៅចូលរួមចំណែកក្នុងការកាត់បន្ថយភាពចង្អៀតណែនក្នុងពន្ធនាគារ ក្រសួងយុត្តិធម៌បានចេញសេចក្តីណែនាំលេខ ០១ កយ.សណន/២០ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ដោយបានណែនាំអំពីគោលការណ៍ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ សម្រាប់យុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងព្រហ្មទណ្ឌនៅតាមសាលាដំបូងរាជធានី ខេត្ត។

ក្រសួងយុត្តិធម៌ពិនិត្យឃើញថា នៅក្នុងរយៈពេល១ឆ្នាំ ១ខែ នៃការអនុវត្តយុទ្ធនាការខាងលើ, សាលាដំបូងរាជធានី ខេត្តបានចូលរួមអនុវត្តប្រកបដោយការយកចិត្តទុកដាក់ និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់នូវគោលការណ៍ណែនាំដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលទាំង ៣ ខាងលើ នៃដំណើរការនីតិវិធីតុលាការ។ ជាលទ្ធផលឃើញថា ទាំងសំណុំរឿងព្រហ្មទណ្ឌដែលកកស្ទះ ទាំងសំណុំរឿងព្រហ្មទណ្ឌដែលចូលថ្មីជាច្រើនត្រូវបានតុលាការចាត់ការបានយ៉ាងឆាប់រហ័ស ស្របតាមនីតិវិធីច្បាប់ ហើយបានចូលរួមចំណែកក្នុងការកាត់បន្ថយភាពចង្អៀតណែនក្នុងពន្ធនាគារបានមួយកម្រិតផងដែរ ដែលមានខ្លឹមសារលម្អិតដូចមានក្នុងសេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងយុត្តិធម៌។

ដោយផ្អែកលើលទ្ធផលល្អប្រសើរនៃការអនុវត្តគោលការណ៍ណែនាំ ក្នុងក្របខណ្ឌនៃការអនុវត្តយុទ្ធនាការខាងលើ និងដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ, ក្រមព្រហ្មទណ្ឌ ព្រមទាំងសេចក្តីណែនាំ រួមនឹងសារាចរពាក់ព័ន្ធនានា ក៏ដូចជាដើម្បីពន្លឿនចំណាត់ការនីតិវិធីនៅក្នុងសំណុំរឿង និងដើម្បីចូលរួមចំណែកដោះស្រាយភាពចង្អៀតណែនក្នុងពន្ធនាគារ ពិសេសក្នុងបរិបទនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្រសួងយុត្តិធម៌សូមធ្វើការណែនាំជាថ្មីដល់សាលាដំបូងរាជធានី ខេត្ត ឱ្យបន្តអនុវត្តគោលការណ៍ណែនាំ

ដែលត្រូវបានកំណត់នៅក្នុងសេចក្តីណែនាំលេខ ០១ កយ.សណន/២០ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ដែលក្រសួងយុត្តិធម៌សូមរំលឹកឡើងវិញអំពីខ្លឹមសារសំខាន់ៗ ដូចតទៅ៖

## ១-អំពីគោលការណ៍នៅក្នុងដំណាក់កាលអយ្យការ

វិធីនៃការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ មានចែងនៅក្នុងមាត្រា ៤៣ និងមាត្រាពាក់ព័ន្ធបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ យោងតាមមាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិធីនៃការចោទប្រកាន់រួមមាន៖ (១)-ការបើកការស៊ើបសួរ (២)-ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និង(៣)-ការបង្ហាញខ្លួនភ្លាម។ កន្លងមក ក្រសួងយុត្តិធម៌បានពិនិត្យឃើញថា អយ្យការអមសាលាដំបូងរាជធានី ខេត្ត ពុំសូវបានប្រើវិធីចោទ-ប្រកាន់ តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬការបង្ហាញខ្លួនភ្លាមនោះទេ ក៏ប៉ុន្តែតែងប្រើវិធីចោទប្រកាន់ចំពោះបទមជ្ឈិមតាមរយៈការបើកការស៊ើបសួរ ដែលជាបច្ច័យនាំឱ្យមានការកើនឡើងជាច្រើននូវសំណុំរឿងនៅក្នុងដំណាក់កាលស៊ើបសួរ។

ដើម្បីពន្លឿនចំណាត់ការលើសំណុំរឿង ជាពិសេសការកាត់បន្ថយការកកស្ទះសំណុំរឿងនៅក្នុងដំណាក់កាលស៊ើបសួរ ក្រសួងយុត្តិធម៌សូមធ្វើការណែនាំ និងលើកទឹកចិត្តឱ្យអយ្យការអមសាលាដំបូងរាជធានី ខេត្តទាំងអស់ យកចិត្តទុកដាក់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការផ្តល់អាទិភាពប្រើវិធីចោទប្រកាន់ចំពោះបទមជ្ឈិម តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬការបង្ហាញខ្លួនភ្លាម ដោយផ្អែកតាមអង្គហេតុនៅក្នុងសំណុំរឿងនីមួយៗ និងផ្អែកតាមលក្ខខណ្ឌ និងនីតិវិធីដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

## ២-អំពីគោលការណ៍នៅក្នុងដំណាក់កាលស៊ើបសួរ

គោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន មានចែងនៅក្នុងមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ យោងតាមស្មារតីនៃមាត្រា ២០៣ នេះ ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព ហើយក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្នក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ទន្ទឹមនេះ ក្រមនីតិវិធីព្រហ្មទណ្ឌក៏ចែងផងដែរអំពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលជាវិធានការនិរន្តរាយមួយដែលអាចយកទៅប្រើ ដើម្បីធានាដល់ដំណើរការនីតិវិធីនៃការស៊ើបសួរ ជំនួសឱ្យវិធានការនៃការឃុំខ្លួនបណ្តោះអាសន្ន តាមរយៈការដាក់ឱ្យជនត្រូវចោទជាប់នូវកាតព្វកិច្ចមួយចំនួនដូចមានចែងក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

កន្លងមក ក្រសួងយុត្តិធម៌បានពិនិត្យឃើញថា វិធានការនៃការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការពុំសូវត្រូវបានប្រើឱ្យបានទូលំទូលាយស្របតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌនៅឡើយទេ ហើយជាទូទៅ ចៅក្រមស៊ើបសួរបានប្រើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការសម្រេចជ្រើសយកការឃុំខ្លួនបណ្តោះអាសន្នជាវិធានការនិរន្តរាយ ដើម្បីធានាដល់ដំណើរការនៃការស៊ើបសួរ ដែលជាកត្តារួមចំណែកនាំឱ្យមានការកើនឡើងនៃជនជាប់ឃុំនៅតាមពន្ធនាគារ។

ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយភាពចង្អៀតណែននៅតាមពន្ធនាគារ ក្រសួងយុត្តិធម៌សូមធ្វើការណែនាំចំពោះការអនុវត្តវិធានការនិរន្តរាយនៅក្នុងដំណាក់កាលស៊ើបសួរដូចតទៅ៖

-ចៅក្រមស៊ើបសួរ គប្បីយកចិត្តទុកដាក់ក្នុងការពន្លឿនការអនុវត្តនីតិវិធីស៊ើបសួររបស់ខ្លួនឱ្យបានឆាប់រហ័ស ប្រកបដោយស្មារតីទទួលខុសត្រូវចំពោះមុខច្បាប់ និងស្របតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-ចៅក្រមស៊ើបសួរ គប្បីយកចិត្តទុកដាក់ប្រើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការអនុវត្តឱ្យបានត្រឹមត្រូវស្របតាមមាត្រា ២០៣ និងមាត្រាពាក់ព័ន្ធបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន ជាពិសេសស្មារតីនៃការគោរពគោលការណ៍សេរីភាពជាចម្បង និងគោលការណ៍សន្មតទុកជាមុនថាគ្មានទោស។ ការឃុំខ្លួនបណ្ដោះអាសន្ន គប្បីត្រូវបានប្រើសម្រាប់តែចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលមានភាពស្មុគស្មាញ និងធ្ងន់ធ្ងរ ហើយក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌជាពិសេស ក្នុងករណីដែលការឃុំខ្លួនបណ្ដោះអាសន្ននោះ គឺជាមធ្យោបាយតែមួយគត់ និងចាំបាច់ដើម្បីធានាដល់ដំណើរការស៊ើបសួរតែប៉ុណ្ណោះ។

-លើកទឹកចិត្តឱ្យចៅក្រមស៊ើបសួរប្រើឱ្យអស់លទ្ធភាព និងឱ្យបានទូលំទូលាយ ដោយផ្អែកតាមអង្គហេតុជាក់ស្ដែងនៃសំណុំរឿងនីមួយៗ ក្នុងការសម្រេចជ្រើសសយកការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ជាវិធានការនិរន្តរាយ ជំនួសឱ្យវិធានការនៃការឃុំខ្លួនបណ្ដោះអាសន្ន ដើម្បីធានាដល់ដំណើរការនៃការស៊ើបសួរ ស្របតាមបញ្ញត្តិចាប់ពីមាត្រា ២២៣ ដល់មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាពិសេសចំពោះបទមជ្ឈិមដែលមិនមានភាពស្មុគស្មាញ និងមិនធ្ងន់ធ្ងរ។ ក្នុងករណីដែលវិធានការនេះត្រូវបានប្រើ, ចៅក្រមស៊ើបសួរត្រូវយកចិត្តទុកដាក់បន្ថែមទៀតក្នុងការអនុវត្តតាមស្មារតីនៃសារាចរលេខ ០១ កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌។

## ៣-អំពីគោលការណ៍នៅក្នុងដំណាក់កាលជំនុំជម្រះ

របបនៃការប្រកាសទោសមានចែងនៅក្នុងក្រមព្រហ្មទណ្ឌត្រង់គន្ថីទី១ មាតិកាទី៣ ជំពូកទី៣។ យោងតាមស្មារតីនៃក្រមព្រហ្មទណ្ឌ ការសម្រេចអំពីទោស គឺជាឆន្ទានុសិទ្ធិរបស់ចៅក្រម ប៉ុន្តែ ការសម្រេចនេះ ជាទូទៅ ត្រូវផ្អែកលើមូលដ្ឋាននៃការការពារផលប្រយោជន៍ផ្នែកសន្តិសុខសាធារណៈ និងសណ្ដាប់ធ្នាប់សង្គម ការការពារសិទ្ធិបុគ្គលស្របតាមច្បាប់ និងជាពិសេសការបម្រើឱ្យគោលបំណងនៃទោសព្រហ្មទណ្ឌក្នុងការបង្ការ ទប់ស្កាត់ការប្រព្រឹត្តបទល្មើសនាពេលអនាគត ក៏ដូចជាអប់រំកែប្រែទណ្ឌិតឱ្យចូលទៅរួមរស់នៅក្នុងសង្គមជាតិវិញ។

ផ្អែកតាមស្មារតីនេះ និងដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយភាពចង្អៀតណែននៅតាមពន្ធនាគារ ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចតទៅ៖

-តុលាការ គប្បីយកចិត្តទុកដាក់ក្នុងការពន្លឿនការបើកសវនាការ និងចេញសាលក្រម ឱ្យបានឆាប់រហ័ស ប្រកបដោយស្មារតីទទួលខុសត្រូវចំពោះមុខច្បាប់ និងស្របតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-ចំពោះការអនុវត្តរបបនៃការប្រកាសទោស តុលាការគប្បីពិចារណាប្រកាសទោសដោយមានការចាត់ចែងក្នុងការអនុវត្ត ដោយផ្អែកតាមគោលការណ៍ឯកត្តកម្មនៃទោស, អង្គហេតុនៃបទល្មើស, កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស និងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ សំដៅធានាដល់គោលបំណងនៃទោសស្របតាមស្មារតីនៃច្បាប់។ ទន្ទឹមនេះ ដោយផ្អែកតាមអង្គហេតុជាក់ស្ដែងនៃសំណុំរឿងនីមួយៗ តុលាការត្រូវបានលើកទឹកចិត្តឱ្យប្រើរបបនៃការព្យួរទោស ជាពិសេសការព្យួរទោសសាកល្បងឱ្យអស់លទ្ធភាព និងឱ្យបានទូលំទូលាយ ផ្អែកតាមអង្គហេតុជាក់ស្ដែងនៃសំណុំរឿងនីមួយៗ ដើម្បីផ្ដន្ទាទោសជនជាប់ចោទស្របតាមបញ្ញត្តិចាប់ពីមាត្រា ១០៤ ដល់មាត្រា ១២៣ នៃក្រមព្រហ្មទណ្ឌ ជាពិសេសចំពោះបទមជ្ឈិម

ដែលមិនមានភាពស្មុគស្មាញ និងមិនធ្ងន់ធ្ងរ។ ក្នុងករណីដែលតុលាការសម្រេចជ្រើសយកការប្រកាសការព្យួរទោសសាកល្បង តុលាការត្រូវយកចិត្តទុកដាក់បន្ថែមទៀតក្នុងការអនុវត្តតាមស្មារតីនៃសារាចរ លេខ ០២ កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌។

ទទួលបានការណែនាំនេះ **ឯកឧត្តម លោកជំទាវ** ជាប្រធានសាលាដំបូង និងជាព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ត្រូវចាត់ចែងអនុវត្ត និងណែនាំអនុវត្តដល់ចៅក្រម ព្រះរាជអាជ្ញារង និងតួអង្គពាក់ព័ន្ធនៅតាមអង្គភាពរបស់ខ្លួន ឱ្យមានប្រសិទ្ធភាព ស្របតាមគោលបំណង និងស្មារតីនៃច្បាប់ សំដៅបង្កើនប្រសិទ្ធភាពនៃយុត្តិធម៌ព្រហ្មទណ្ឌ និងពង្រឹងនីតិរដ្ឋនៅកម្ពុជា។

ថ្ងៃ ចន្ទ ៥ រោច ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**កើត រិទ្ធ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- តុលាការកំពូល និងមហាអយ្យអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
- ឯកសារ-កាលប្បវត្តិ